

# ចេតសិក ចិត្ត និងបរមត្ថសច្ចៈ

# ចេតសិក

**ឯកុប្បាទ និរោធាច ឯកាលម្ពណវត្ថុកា ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា**
ដែលហៅថា ចេតសិកគឺ ធម៌៥២ ដែលៈ
- កើតឡើងព្រមជាមួយនឹងចិត្ត
- រលត់ព្រមជាមួយនឹងចិត្ត
- មានអារម្មណ៍ដូចគ្នានឹងរបស់ចិត្ត
- មានឫសគល់ជាមួយនឹងចិត្ត ។

ចេតសិក៥០ (ចេតសិក៥២លើកលែងវេទនានិងសញ្ញាចេញ) ហៅថា សង្ខារ ។ តើចេតសិក៥២នោះមានអ្វីខ្លះ? សូមរាប់រៀបដូចតទៅ៖

**សព្វចិត្តសាធារណា - ៧**
សព្វចិត្តសាធារណៈ មាន៧គឺៈ

១- ផស្សោ (អារម្មណ៍ពាល់ត្រូវ),
២- វេទនា (ការសើយអារម្មណ៍),
៣- សញ្ញា (ការចាំ),
៤- ចេតនា (ការចង់),
៥- ឯកគ្គតា (អារម្មណ៍មូលតែមួយ),
៦- ជីវិតិន្ទ្រិយ (ឥន្ទ្រិយគឺការរស់),
៧- មនសិការោ (ការប្រុងប្រយ័ត្ន) ។

សព្វចិត្តសាធារណៈចេតសិកនេះ តែងកើតមានគ្រប់ចិត្ត ទាំងឡាយ ។

## បកិណ្ណកា - ៦

បកិណ្ណកៈចេតសិកមាន៦គឺៈ

១- វិតក្កោ (ការឡើងកាន់អារម្មណ៍),

២- វិចារោ (ការពិចារណាអារម្មណ៍),

៣- អធិមោក្ខោ (ការចូលស៊ប់ក្នុងអារម្មណ៍),

៤- វិរិយៈ (ការព្យាយាមឲ្យសម្រេចផល),

៥- បីតិ (ការរំភើបនៃអារម្មណ៍),

៦- ឆន្ទៈ (ការពេញចិត្តនិងធ្វើ) ។

បកិណ្ណកៈចេតសិកនេះហៅថាចេតសិកពិសេសតែងមានលាយឡំជាមួយគ្នា នឹងសព្វសាធារណៈ ។ ចេតសិកទាំង១៣នេះហៅថា អញ្ញសមានា ចេតសិក ។

## អកុសលា - ១៤

អកុសលចេតសិកមាន១៤គឺៈ

១- មោហោ (សេចក្ដីល្ងង់ខ្លៅ),

២- អហិរិកៈ (ការមិនខ្មាស់បាប),

៣- អនោត្តប្បៈ (ការមិនខ្លាចបាប),

៤- ឧទ្ធច្ចៈ (ការរជ្រួលប្រូបស់),

៥- លោភោ (ការជំពាក់អារម្មណ៍ដោយកាម),

៦- ទិដ្ឋិ (ការយល់ខុស),

៧- មានោ(សេចក្ដីរឹងរុះ),

៨- ទោសោ (ការប្រទុសអារម្មណ៍ដោយស្អប់),

៩- ឥស្សា (ការប្រណែន),

១0- មច្ឆរិយៈ (សេចក្ដីកំណាញ់),

១១- កុក្កុច្ចៈ (ការស្ដាយ),

១២- ថីនៈ (ការខ្ជិលច្រអូស),

១៣- មិទ្ធៈ (ការខ្វះសមត្ថភាព),

១៤- វិចិកិច្ឆា (សេចក្តីសង្ស័យ) ។

ចេតសិក១៤នេះឈ្មោះថា អកុសលចេតសិក ។

## សោភណសាធារណា - ១៩

សោភណសាធារណៈចេតសិកមាន១៩គឺៈ

១- សទ្ធា (ជំនឿទុកចិត្ត),

២- សតិ (សេចក្តីរលឹក),

៣- ហិរិ (ការខ្មាស់បាប),

៤- ឱត្តប្បៈ (ការខ្លាចបាប),

៥- អលោភោ (ការមិនជំពាក់អារម្មណ៍),

៦- អទោសោ (ការមិនប្រទុសអារម្មណ៍),

៧- តត្រមជ្ឈត្តតា (ភាពជាអព្យាក្រិត្យ),

៨- កាយបស្សទ្ធិ (សេចក្តីស្ងប់កាយ),

៩- ចិត្តបស្សទ្ធិ (សេចក្តីស្ងប់ ចិត្ត),

១០- កាយលហុតា (សេចក្តីស្រាលរហ័សកាយ),

១១- ចិត្តលហុតា (សេចក្តី ស្រាលរហ័សចិត្ត),

១២- កាយមុទុតា (សេចក្តីមិនរឹងតឹងកាយ),

១៣- ចិត្តមុទុតា (សេចក្តីមិនរឹងតឹងចិត្ត),

១៤- កាយកម្មញ្ញតា (ការប្រើបាននៃកាយ),

១៥- ចិត្តកម្មញ្ញតា (ការប្រើបាននៃចិត្ត),

១៦- កាយបាគុញ្ញតា (ការប៉ិនប្រសប់កាយ),

១៧- ចិត្តបាគុញ្ញតា (ការប៉ិនប្រសប់ចិត្ត),

១៨-កាយុជ្ជុកតា (ការត្រង់ចំនៃកាយ),

១៩- ចិត្តុជ្ជុកតា (ការត្រង់ ចំនៃចិត្ត) ។

ចេតសិក១៩នេះ មានឈ្មោះ ថា សោភ័ណ្ណចេតសិក(ល្អប្រពៃ) ។

**វិរតិយោ - ៣**

វិរតិចេតសិកមាន៣គឺ:

១- សម្មាវាចា (វាចាត្រូវ),

២- សម្មាកម្មន្តោ (ការងារត្រូវ),

៣- សម្មាអាជីវោ (ការចិញ្ចឹមជីវិតត្រូវ) ។

ចេតសិកទាំង៣នេះមានឈ្មោះថា វិរតិចេត សិក (ចេតសិកនៃការវៀរចាកវាចាខុស, អំពើដោយកាយខុសមានការសម្លាប់សត្វ- លួចទ្រព្យគេ- ប្រព្រឹត្តខុសក្នុងកាម និងការប្រកបរបរចិញ្ចឹមជីវិតខុស) ។

**អប្បមញ្ញា - ២**

អប្បមញ្ញាចេតសិកមាន២គឺ:

១- ករុណា (សេចក្តីអាណិតអាសូរ),

២- មុទិតា (សេចក្តីត្រេកអរនឹងការបានចំរើនរបស់អ្នកដទៃ) ។

ចេតសិកទាំង២នេះ ហៅថាអប្បមញ្ញាចេតសិក ។

**បញ្ញិន្ទ្រិយ - ១**

បញ្ញាចេតសិកមាន១គឺ:

១- បញ្ញា (សេចក្តីយល់ដឹងដោយត្រឹមត្រូវ) ។

សោភ័ណ្ណសាធារណចេតសិក១៩, វិរតិចេតសិក៣, អប្បមញ្ញាចេតសិក២ និង បញ្ញិន្ទ្រិយចេតសិក១ ទាំងអស់២៥ចេតសិកនេះ ឈ្មោះថា សោភ័ណ្ណចេតសិក ទាំងអស់ ។

មេត្តា ស្ថិតនៅក្នុង អទោសោចេតសិកហើយ ឧបេក្ខា ក៏ស្ថិតនៅក្នុងតត្រមជ្ឈត្តតា ចេតសិករួចហើយ ទើបមិនលើកយកមករាប់បញ្ចូលក្នុងទីនេះ ។

សព្វសាធារណចេតសិក៧ កើតមាននៅគ្រប់ចិត្ត៨៩ ។ បកិណ្ណកចេតសិក៦ កើតឡើងតាមកាលៈទេសៈដែលគួរនឹងកើត ដូចជារូបាវចរចិត្តជាដើម ។ អកុសល ចេតសិក ១៤ កើតតែក្នុងអកុសលចិត្ត១២ ប៉ុណ្ណោះ ។



# ចិត្ត៨៩ ឬ ចិត្ត១២១

កាមាវចរចិត្ត៥៤ + រូបាវចរចិត្ត១៥ + អរូបាវចរចិត្ត១២ + លោកុត្តរចិត្ត៨ = ៨៩

## កាមាវចរចិត្ត

កាមាវចរចិត្ត៥៤ = អកុសលចិត្ត១២ + អហេតុកចិត្ត១៨ + សោភណៈចិត្ត២៤

- អកុសលចិត្ត១២ = លោភៈចិត្ត៨ + ទោសៈចិត្ត២ + មោហៈចិត្ត២
- អហេតុកចិត្ត១៨ = អកុសលវិបាកចិត្ត៧ + កុសលវិបាកចិត្ត៨ + កិរិយាចិត្ត៣
- សោភណៈចិត្ត២៤ = កុសលចិត្ត៨ + វិបាកចិត្ត៨ + កិរិយាចិត្ត៨

## រូបាវចរចិត្ត

រូបាវចរចិត្ត១៥ (មហគ្គតៈឈាន) = កុសលចិត្ត៥ + វិបាកចិត្ត៥ + កិរិយាចិត្ត៥

## អរូបាវចរចិត្ត

អរូបាវចរចិត្ត១២ = កុសលចិត្ត៤ + វិបាកចិត្ត៤ + កិរិយាចិត្ត៤

## លោកុត្តរចិត្ត

លោកុត្តរចិត្ត៨ = មគ្គចិត្ត៤ + ផលចិត្ត៤

ចិត្តទាំងអស់ដែលរាប់រៀបខាងលើនេះ មានចំនួន៨៩ ។ ប៉ុន្តែបើរាប់តាមឈាន លោកុត្តចិត្តមានទាំងអស់៤០ (មិនមែនមានត្រឹមតែ៨ទេ) គឺថាលោកុត្តរឈានមាន៥ ហើយមគ្គចិត្ត៤ និងផលចិត្ត៤ គុណនឹងឈាន៥ ត្រូវជា មគ្គចិត្ត២០ និង ផលចិត្ត២០ ត្រូវជា៤០ ។

កាមាវចរចិត្ត៥៤ + រូបាវចរចិត្ត១៥ + អរូបាវចរចិត្ត១២ + លោកុត្តរចិត្ត៤០ = ចិត្ត១២១

ជាធម្មតា គេតែងរាប់ចិត្ត៨៩ សេចក្ដីនេះមិនមែនមានន័យថា បុគ្គលម្នាក់ ៗ មានចិត្ត៨៩នោះឡើយ ព្រោះចិត្តមិនកើតឡើងឯង ៗ នោះទេ យោគាវចរទាំងឡាយបណ្ដុះចិត្តមានរូបាវចរចិត្តជាដើម ឲ្យកើតឡើង តាមការបំពេញឈាន គឺសមាធិ និង វិបស្សនា កម្មដ្ឋាន ។ ហេតុដូច្នេះហើយ បានជាសមាធិនិងវិបស្សនា ជាវិធីសំខាន់បំផុត ក្នុងការបដិបត្តិព្រះធម៌ ។ បុគ្គលដែលធ្វើតែសីលនិងទាន គ្មានសមាធិ-វិបស្សនា មានត្រឹមតែ **កាមាវចរចិត្ត** ដែលឲ្យសត្វកើតក្នុងឋានមនុស្សនិងឋានសួគ៌ មិនអាចកើតក្នុងឋានរូប ព្រហ្ម, អរូបព្រហ្ម ឬសម្រេចព្រះនិព្វានបានឡើយ ។ **រូបាវចរចិត្ត** ឲ្យសត្វទៅកើតក្នុងឋានរូបព្រហ្ម **អរូបាវចរចិត្ត** ឲ្យសត្វទៅកើតក្នុងឋានអរូបព្រហ្ម ។ **លោកុត្តរចិត្ត** ជាចិត្តបរិសុទ្ធ រួចចាកអាសវៈកិលេសទាំងពួង ឥតមានសេសសល់ ។ ព្រះយោគាវចរដែលបានសម្រេចអរហត្តផលពេញបរិបូណ៌ មិនវិលត្រឡប់ កើតក្នុងភព៣ទៀតឡើយ ព្រះអង្គចូលទៅកាន់ព្រះនិព្វានដែលជាស្ថានបរមសុខ ។ ព្រះយោគាវចរដែលបានសម្រេចមគ្គចិត្ត - ផលចិត្ត តែមិនទាន់ដល់អរហត្តផល នឹង ទៅកើតក្នុងឋានព្រហ្ម មានវេហប្ផលព្រហ្មជាដើម ។

រីឯភពទាំង៣ ឬត្រៃភព គឺ កាមាវចរភព (កាមភព) ១, រូបាវចរភព (រូបភព) ១ និងអរូបាវចរភព (អរូបភព) ១ សូមលើកយកមកអធិប្បាយដោយខ្លី ៗ ដូចតទៅ៖

## កាមាលោក

**កាមាលោក** មាន ១១ឋាន គឺ អបាយភូមិ៤, ឋានមនុស្ស១ និងឋានសួគ៌៦ ។

**១- អបាយភូមិ៤** គឺ នរក១, តិរច្ឆាន១, ប្រេត១ និងអសុរកាយ១ ។ ជនដែលបានប្រព្រឹត្តនូវអកុសលកម្ម មានពៀរ៥យ៉ាងគឺៈ សម្លាប់សត្វ១ លួចទ្រព្យគេ១ ប្រព្រឹត្តខុស

ក្នុងកាម១ ភូតកុហក១ និងផឹកសុរានិងមេរ័យ្យ១ ជនទាំងនោះទៅកើតក្នុងភពនរក តិរច្ឆាន ប្រេត អសុរកាយ បើបានកើតជាមនុស្ស ក៏មនុស្សនោះរងទុក្ខវេទនាជាខ្លាំង ។

**២- ឋានមនុស្ស** គឺជនដែលវៀរចាកពៀរ៥យ៉ាងដូចពោលមកខាងលើ មកកើតក្នុងឋានមនុស្សដែលសុខនិងទុក្ខនៅលាយឡំគ្នា ។ សត្វដែលរួចផុតកម្មអំពីអបាយភូមិក៏អាចមកកើតក្នុងឋានមនុស្សដែរ ។ ទេវតាដែលអស់បុណ្យអំពីឋានសួគ៌ ក៏មកកើតក្នុងឋានមនុស្ស តែទេវតាអស់បុណ្យទាំងនោះមិនទទួលរងទុក្ខខ្លាំងដូចជនដែល ជាប់កម្មក្នុងពៀរ៥យ៉ាងនោះឡើយ ។ ព្រះពោធិសត្វក៏មកកើតជាមនុស្សមុននឹងបានត្រាស់ជាព្រះពុទ្ធ ។ មនុស្សជាអ្នកមានឧប្បនិស្ស័យខ្ពង់ខ្ពស់ ព្រោះថាអាចកើតទាន់សាសនាព្រះពុទ្ធ ហើយប្រតិបត្តិធម៌ សីល- សមាធិ- បញ្ញា រហូតដល់សម្រេចព្រះនិព្វានបាន ។

**៣- ឋានសួគ៌៦ជាន់** គឺ ៖

- **ចាតុម្មហារាជដិកៈ** ជាឋានរបស់មហារាជទាំង៤គឺ គន្ធព្វ (ទេវតារាំ ច្រៀង)១, យក្ខ១, នាគ១, គ្រុឌ១ ។ ទេវតាទាំងនេះមានអាយុកំរិត៥00 ឆ្នាំទិព្វ ។ ១ថ្ងៃ១យប់នៅឋានសួគ៌ស្មើនឹង៥0ឆ្នាំនៅឋានមនុស្ស ។ ៥00ឆ្នាំទិព្វស្មើនឹង ៩,000,000ឆ្នាំមនុស្ស ។
- **តាវតឹង្សៈ** ទេវតាឋានតាវតឹង្ស មានអាយុកំរិត ១,000ឆ្នាំទិព្វ ។
- **យាមៈ** ទេវតាឋានយាមៈ មានអាយុកំរិត ២,000 ឆ្នាំទិព្វ ។
- **តុសិតៈ** ទេវតាឋានតុសិត មានអាយុកំរិត៤,000 ឆ្នាំទិព្វ ។
- **និម្មានរតិ** ទេវតាឋាននិម្មានរតី មានអាយុកំរិត៨,000 ឆ្នាំទិព្វ ។
- **បរនិម្មិត្តវសវត្តិ** ទេវតាឋានបរនិម្មិត្តវសវត្តី ជាឋានខ្ពស់ជាងគេក្នុងកាមាសួគ៌ មានអាយុកំរិត ១៦,000 ឆ្នាំទិព្វ ។

ទេវតាដែលរក្សាមនុស្សលោក គឺពពួកគន្ធព្វទេវតាពីឋានចាតុម្មហារាជិកៈ ។ ជនដែលរក្សានូវសីលមិនឲ្យដាច់ បូជាចំពោះព្រះរតនត្រៃ ព្រះពុទ្ធ- ព្រះធម៌- ព្រះសង្ឃ ធ្វើទាន ភាវនា សំអាតចិត្ត គោរពមាតាបិតារបស់ខ្លួនលុះស្លាប់ទៅ នឹងទៅកើតក្នុងឋានសួគ៌ ខ្ពស់ទាបទៅតាមអំណាចនៃកុសលកម្មរៀងខ្លួន ។

ទេវតានៃឋានបរនិម្មិតវសវត្តី ជាព្រះអាទិទេព ដែលគ្រប់គ្រងលើអាទិទេពដទៃ ឯទៀត ។ ទេវតាទាំងឡាយតែងមានការគោរពចំពោះព្រះព្រហ្ម ដែលមានឋានៈនិងអំណាចខ្ពង់ខ្ពស់ជាង ។

**រូបលោក**

**រូបលោក** គឺឋានរបស់ព្រះព្រហ្មដែលមានរូប ( ខ្លួន- ប្រាណ ) ។ ជនដែលធ្វើនូវមហគ្គតៈឈាន គឺជាបានដល់នូវការសម្រេចឈានក្នុងការធ្វើកម្មដ្ឋានណាមួយក្នុងកម្មដ្ឋាន៣៦ មានកសិណ១០, អសុភ១០, អនុស្សតិ១០, ព្រហ្មវិហារ៤, សញ្ញា១, វវដ្ឋាន១ ជននោះក្រោយពេលអស់អាយុអំពីលោកនេះទៅ នឹងទៅកើតក្នុងឋានរូបព្រហ្ម ដែលរាប់រៀបតាមឈានដូចតទៅ៖

**បឋមជ្ឈានភូមិ** ( ឈានទី១ )

- ព្រហ្មបរិសជ្ជា អាយុព្រហ្មមានកំរិត១ភាគ៣នៃអសង្ខេយ្យកប្ប ។
- ព្រហ្មបុរោហិតៈ អាយុព្រហ្មមានកំរិតកន្លះនៃអសង្ខេយ្យកប្ប ។
- មហាព្រហ្មា អាយុព្រហ្មមានកំរិត១អសង្ខេយ្យកប្ប ។

(រយៈពេលចាប់តាំងពីមនុស្សអាយុបានតែត្រឹម១០ឆ្នាំស្លាប់ ដល់ពេលមនុស្សមានអាយុវែងមិនកំណត់ រហូតដល់មនុស្សអាយុបានតែត្រឹម១០ឆ្នាំស្លាប់វិញ ១ជុំនេះហៅថា ១អន្តរកប្ប ។ ២០អន្តរកប្បស្មើនឹង១អសង្ខេយ្យកប្ប ។ ៤អសង្ខេយ្យកប្បស្មើនឹង១មហាកប្ប )

**ទុតិយជ្ឈានភូមិ** ( ឈានទី២ )

- បរិត្តាភា អាយុព្រហ្មមានកំរិត២មហាកប្ប ។
- អប្បមាណាភា អាយុព្រហ្មមានកំរិត៤មហាកប្ប ។
- អាភស្សរា អាយុព្រហ្មមានកំរិត៨មហាកប្ប ។

**តតិយជ្ឈានភូមិ** ( ឈានទី៣ )

- បរិត្តាសុភៈ អាយុព្រហ្មមានកំរិត១៦មហាកប្ប ។
- អប្បមាណសុភៈ អាយុព្រហ្មមានកំរិត៣២មហាកប្ប ។

- សុភកិណ្ហៈ អាយុព្រហ្មមានកំរិត៦៤មហាកប្ប ។

**ចតុត្ថជ្ឈានភូមិ និងបញ្ចមជ្ឈានភូមិ ហៅ សុទ្ធាវាស** ( ឈានទី៤ ទី៥ )

- វេហប្ផលៈ អាយុព្រហ្មមានកំរិត៥០០មហាកប្ប ។
- អសញ្ញសត្តៈ អាយុព្រហ្មមានកំរិត៥០០មហាកប្ប ។
- អវិហា អាយុព្រហ្មមានកំរិត១,០០០មហាកប្ប ។
- អតប្បា អាយុព្រហ្មមានកំរិត២,០០០មហាកប្ប ។
- សុទស្សា អាយុព្រហ្មមានកំរិត៤,០០០មហាកប្ប ។
- សុទស្សី អាយុព្រហ្មមានកំរិត៨,០០០មហាកប្ប ។
- អកណិដ្ឋា អាយុព្រហ្មមានកំរិត១៦,០០០មហាកប្ប ។

ព្រះសោតាបន្ន និងព្រះសកទាគាមិ ដែលសម្រេចឈានទី៥ ទៅកើតក្នុងឋានវេហប្ផលព្រហ្ម ។ ព្រះអនាគាមិ និង ព្រះអរហន្ត កើតក្នុងសទ្ធាវាសព្រហ្មនេះរហូត ដល់បានសម្រេចអរហត្តផលពេញបរិបូណ៌ ហើយក៏ចូលទៅកាន់បរិនិព្វានទៅ ។

## អរូបលោក

**អរូបលោក** ជាឋានរបស់ព្រះព្រហ្មឥតរូប គឺឋាមានតែចិត្ត មិនមានខ្លួន ប្រាណទ្បើយ ។ អរូបលោកនេះជាឋានខ្ពស់ជាងគេបំផុត មាន៤ថ្នាក់គឺៈ

- អាកាសានញ្ចាយតនៈ អាយុព្រហ្មមានកំរិត២០,០០០មហាកប្ប ។
- វិញ្ញាណញ្ចាយតនៈ អាយុព្រហ្មមានកំរិត៤០,០០០មហាកប្ប ។
- អាកិញ្ចញ្ញាយតនៈ អាយុព្រហ្មមានកំរិត៦០,០០០មហាកប្ប ។
- នេវសញ្ញានាសញ្ញាយតនៈ អាយុព្រហ្មមានកំរិត៨៤,០០០មហាកប្ប ។

ព្រះយោគាវចរដែលចំរើន **អារុប្បជ្ឈាន៤** ទៅកើតក្នុងអរូបលោកនេះ រហូតដល់បានសម្រេចអរហត្តផលក៏បរិនិព្វានទៅ ។ អរុប្បជ្ឈាន៤នោះគឺៈ

**១- អាកាសានញ្ចាយតនៈ** យកអាកាសក្នុងបដិភាគនិម្មិតដែលកើតពី កសិណ ជាអារម្មណ៍ ។

**២- វិញ្ញាណញ្ចាយតនៈ** ស្រាវយកអរូបវិញ្ញាណទី១ ដែលផ្សាយទៅមិនមានទីបំផុត ជាអារម្មណ៍ ។

**៣- អាកិញ្ចញ្ញាយតនៈ** កំណត់យកអរូបវិញ្ញាណទី២ ដែលផ្សាយទៅមិនមានកង្វល់តិចតួចមកជាអារម្មណ៍ ។

**៤- នេវសញ្ញានាសញ្ញាយតនៈ** កំណត់យកសេចក្តីល្អិត របស់អរូប វិញ្ញាណទី៣ ដែលមានស្ទើរតែនឹងមិនមាន មកជាអារម្មណ៍ ។

ព្រះអរហន្តដែលមិនទាន់សម្រេចអរហត្តផលពេញបរិបូណ៌ ហើយបានចំរើនអរុប្បជ្ឈាន ទៅកើតក្នុងអរូបលោកនេះ លុះដល់សម្រេចអរហត្តផលពេញបរិបូណ៌ ហើយក៏បរិនិព្វានទៅ ។

**បរិនិព្វាន** មានន័យថា ស្លាប់ទៅលែងកើតទៀតក្រោយដែលបានសម្រេចអរហត្តផលពេញបរិបូណ៌ហើយ ។ សូមកុំច្រឡំ បរិនិព្វាន នឹង និព្វាន ។

## និព្វាន

**ព្រះនិព្វាន**ជា លោកុត្តរធម៌ (បេញផុតត្រៃលោក) ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហៅថានិព្វាននោះ ព្រោះបេញចាកតណ្ហាដែលជាគ្រឿងដោតក្រង ។

ព្រះនិព្វានមាន២យ៉ាងគឺៈ

**១- សឧបាទិសេសនិព្វាន** រលត់តែកិលេស តែបញ្ចក្ខន្ធនៅមិនទាន់អស់ ។

**២- អនុបាទិសេសនិព្វាន** រលត់កិលេសផង រលត់ទាំងបញ្ចក្ខន្ធផង ។

លោកុត្តរចិត្ត កើតឡើងដោយការចំរើននូវវិបស្សនា គឺការបណ្តុះបញ្ញា ។ មុននឹងចំរើនវិបស្សនាបាន ព្រះយោកាវចរត្រូវតែចំរើនសមាធិ មានអនាបនស្សតិជាដើមឲ្យបានបរិបូណ៌សិន គឺថាត្រូវបាននូវបឋមជ្ឈាន ឬឈានខ្ពស់ជាងនេះ ជាមុនទើបចាប់ផ្តើមចំរើនវិបស្សនាជាក្រោយ ។

ឯវិបស្សនានោះមាន៧ ហៅថា អនុបស្សនា៧ គឺ

**១- អនិច្ចានុបស្សនា,**

**២- ទុក្ខានុបស្សនា,**

**៣- អនត្តានុបស្សនា,**

**៤- និព្វិទានុបស្សនា,**

**៥- វិរាគានុបស្សនា,**

**៦- និរោធានុបស្សនា,**

**៧- បដិនិស្សគ្គានុបស្សនា ។**

លោកុត្តរចិត្ត ឬ លោកុត្តរញាណ មាន៨គឺ **មគ្គញាណ៤** និង **ផលញាណ៤** កើតឡើងដោយសារការចំរើននូវអនុបស្សនា៧ខាងលើនេះ ។ **មគ្គញាណ- ផលញាណ** មាន៤ថ្នាក់ពីទាបទៅខ្ពស់ដូចតទៅ៖

**មគ្គញាណ៤**

**១- សោតាបត្តិមគ្គញាណ** ញាណសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកព្រះ និព្វាននៃបុគ្គលដល់ហើយក្នុងដើមនៃធម៌ ដូចជាខ្សែឈ្មោះថាសោតៈ ។

**២- សកទាគាមិមគ្គញាណ** ញាណសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកព្រះ និព្វាននៃបុគ្គលដែលមកកាន់មនុស្សលោកនេះ អស់វារៈម្តងទៀត ដោយអំណាចនៃបដិសន្ធិ ។

៣- **អនាគាមិមគ្គញាណ** ញាណសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកព្រះ និព្វាននៃបុគ្គលដែលមិនមកកាន់កាមធាតុ ឲ្យដ៏ខាងក្រោមដោយអំណាចបដិសន្ធិឡើយ ។
៤- **អរហត្តមគ្គញាណ** ញាណសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកព្រះ និព្វាននៃបុគ្គលដែលមានកិរិយាធ្វើនូវបាបកម្ម ក្នុងទីស្ងាត់មិនមាន ។

ផលញាណ៤

១- **សោតាបត្តិផលញាណ** ញាណសម្បយុត្តដោយផល គឺកិរិយាសម្រេចនូវ ព្រះ និព្វាននៃបុគ្គលដល់ហើយក្នុងដើមនៃធម៌ ដូចជាខ្សែឈ្មោះថា សោតៈ ។
២- **សកទាគាមិផលញាណ** ញាណសម្បយុត្តដោយផល គឺកិរិយាសម្រេចនូវព្រះនិព្វាន នៃបុគ្គលដែលមកកាន់មនុស្សលោកនេះ អស់វារៈម្តងដោយអំណាចនៃបដិសន្ធិ ។
៣- **អនាគាមិផលញាណ** ញាណសម្បយុត្តដោយផល គឺកិរិយាសម្រេចនូវ ព្រះ និព្វាន នៃបុគ្គល ដែលមិនមកកាន់កាមធាតុ ឲ្យដ៏ខាងក្រោមដោយអំណាចបដិសន្ធិ ឡើយ ។
៤- **អរហត្តផលញាណ** ញាណសម្បយុត្តដោយផល គឺកិរិយាសម្រេចនូវព្រះ និព្វាននៃបុគ្គលដែលមានកិរិយាធ្វើនូវបាបកម្ម ក្នុងទីស្ងាត់មិនមាន ។

សេចក្តីដូចបានអធិប្បាយមកខាងលើ គ្រាន់តែជាសេចក្តីពន្យល់ខ្លី ៗ ដើម្បី បង្ហាញថា តើបុគ្គលប្រតិបត្តិធម៌អ្វី នឹងទៅកើតក្នុងភពណា ហើយថាតើបុគ្គលប្រតិបត្តិធម៌អ្វីដើម្បីឲ្យបានរួចចាកផុតអំពីការកើតស្លាប់ ៗ ក្នុងភព៣ សម្រេចមគ្គនិងផលទៅកាន់ទីឧត្តមឋានគឺ ព្រះនិព្វាន ដែលជាឋានបរមសុខ ។ អ្នកប្រតិបត្តិធម៌ ប្រៀបដូចជា អ្នកអុំទូកបញ្ច្រាសទឹកហូរ តែកាលណាបន្ធូរដៃ ទូកមុខជានឹងរសាត់ថយក្រោយជាមិនខាន ។ ជនណាឃើញដោយបញ្ញាចក្ខុ នូវហេតុដែលនាំឲ្យកើតទុក្ខ ឃើញនូវផ្លូវដែលនាំទៅកាន់ការរំលត់ទុក្ខ ហើយរលាស់ខ្លួនចេញអំពីទុក្ខ ជននោះជាអ្នកឈ្នះនូវកម្លាំង ទឹកហូរបាន ។ បុគ្គលត្រូវតែខំស្វែងរកធម៌ ព្រោះធម៌ពិតគេរកឃើញដោយកម្រ ។ ធម៌ពិតដែលគេរកឃើញដោយកម្រនោះគឺ **សីល- សមាធិ- បញ្ញា** ។ សីល- សមាធិ- បញ្ញា នោះគឺ សេចក្តីបរិសុទ្ធ៧យ៉ាង ហៅថា

**វិសុទ្ធិ៧**នោះឯង ។ រីឯវិសុទ្ធិ៧នោះបែកជាពីរគឺធម៌ជាឫសគល់ (សីលវិសុទ្ធិ១និងចិត្តវិសុទ្ធិ១) និងធម៌ជាតួវិបស្សនា (ទិដ្ឋិវិសុទ្ធិ១, កង្ខា វិតរណវិសុទ្ធិ១, មគ្គាមគ្គញាណទស្សនវិសុទ្ធិ១, បដិបទាញាណទស្សនវិសុទ្ធិ១ និងញាណទស្សនវិសុទ្ធិ១) ។ សីលវិសុទ្ធិ ជាសីល ។ ចិត្តវិសុទ្ធិ ជាសមាធិ ។ ទិដ្ឋិវិសុទ្ធិ១, កង្ខាវិតរណវិសុទ្ធិ១, មគ្គាមគ្គញាណទស្សនវិសុទ្ធិ១, បដិបទាញាណទស្សនវិសុទ្ធិ១ និងញាណទស្សនវិសុទ្ធិ១ ទាំង៥នេះជាបញ្ញា ។

១- **សីលវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃសីល ។

២- **ចិត្តវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃចិត្ត (សមាធិចិត្ត) ។

៣- **ទិដ្ឋិវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃការឃើញ ។

៤- **កង្ខាវិតរណវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃការយល់ឃើញច្បាស់កន្លង សេចក្ដីសង្ស័យបាន ។

៥- **មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃដឹងពិត ស្គាល់ពិតថានេះជាផ្លូវនេះមិនមែនជាផ្លូវ ។

៦- **បដិបទាញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃការដឹងច្បាស់ឃើញច្បាស់នូវផ្លូវប្រតិបត្តិ ដែលជាហេតុឲ្យអរិយមគ្គកើតឡើង ។

៧- **ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃការឃើញនូវករណីយកិច្ច ដែលជាចំណែកនៃលោកុត្តរៈ គឺឃើញក្នុងមគ្គ៤ដោយជាក់ច្បាស់តាមលក្ខណៈនិងសភាវៈ មិន វង្វេងទៅតាមសម្មុតិលោកវោហារថា ជាសត្វជាបុគ្គល យើង- គេ ឡើយ ដែលជាតួទិដ្ឋិវិសុទ្ធិទាំងជាហេតុនិងជាបច្ច័យកន្លងកង្ខាក្នុងកាលទាំង៣បេញបាន គឺមិនសង្ស័យថាយើងច្យុតមកពីទីណា ? យើងជាអ្វី ? យើងនឹងទៅកើតក្នុងទីណា ? ទេវបុត្តទេវតាមានឬមិនមាន ? ដែលជាតួកង្ខាវិតរណវិសុទ្ធិ ។

សង្ខារទាំងឡាយជារបស់មិនទៀង ។ របស់ឯណាមិនទៀង តែកើតឡើងហើយរលត់បាត់បង់ទៅវិញ របស់នោះជាទុក្ខពិត ។ បើរបស់ណាជាទុក្ខ របស់នោះជាអនត្តាមិនគួរ

បើនឹងប្រកៀកប្រកាន់ថាជារបស់ខ្លួន ដោយអំណាចតណ្ហា ឧបាទាន មានះ និងទិដ្ឋិ (យល់ខុស) ឡើយ ។

# សម្មតិសច្ចៈ និង បរមត្ថសច្ចៈ

ក្នុងព្រះអភិធម្មសង្ខេប មានការពន្យល់ថា សច្ចៈ ឬសេចក្តីពិតមាន២គឺៈ

## ១- សម្មតិសច្ចៈ

សម្មតិសច្ចៈ មានន័យថា សេចក្តីពិតដែលមនុស្សជាទូទៅសម្គាល់ ទៅតាមការ មើលឃើញ តាមរូបរាង ពណ៌សម្បុរខាងក្រៅ មិនគិតដល់វត្ថុជាតុខាងក្នុង ឬធម្មជាតិដើមឡើយ ។ ផ្ទះ, រទេះ, គោ, ក្របី, ពូម៉ៅ, តាមួន, ព្រះអាទិត្យ, ព្រះចន្ទ ។ ល ។ ជា សម្មតិសច្ចៈ គឺរូបរាងដូច្នេះ ពណ៌ដូច្នេះ ទំហំយ៉ាងនេះ គេសម្គាល់ថាជារបស់នេះ ជា សត្វនេះ ជាមនុស្សនេះ ។ ដើម្បីបំណាំវត្ថុ សត្វ មនុស្ស គេក៏ដាក់ឈ្មោះឲ្យដើម្បីហៅ កុំឲ្យច្រឡូកច្រឡំគ្នា ។ ការតែងតាំងនាមនេះហៅថា **បញ្ញត្តិ** ។

## ២- បរមត្ថសច្ចៈ

បរមត្ថសច្ចៈ មានន័យថា សេចក្តីពិតតាមធម្មជាតិខាងក្នុង ដែលស្ថិតនៅក្នុង ភាពកំបាំង មិនអាចមើលឃើញដោយងាយ ជាសេចក្តីពិតដែលមិនផ្លាស់ប្តូរដូចជា បរមត្ថសច្ចៈរបស់ផ្ទះនិងរទេះនៅតែជា ឈើ ដដែល គឺជាធម្មជាតិពិត ៗ របស់វា មិនប្តូរ ទៅតាមសភាពខាងក្រៅឡើយ ។

# បញ្ញត្តិ និង បរមត្ថ

អ្វីទាំងឡាយទោះបីជាសម្មុតិក្តី ឬជាបរមត្ថក្តី តែងមានឈ្មោះសម្រាប់ហៅដែលហៅថា **បញ្ញត្តិ** នោះឯង ។ ធម្មជាតិ ដែលបញ្ញត្តិ ធ្វើការតែងតាំងនាមទៅឲ្យ គឺៈ

**១- វត្ថុ** គឺរបស់ផ្សេង ៗ ដូចជា ផ្ទះ, កុដិ, វិហារ, សាលា, មេឃ, ផ្កាយ ជាដើម ។

**២- សត្វ** គឺអ្វី ៗ ដែលមានជីវិតជាប់ជំពាក់ក្នុងបំណងដូចជា គោ, ក្របី, ជ្រូក, ពូសុខ , យាយសៅ ជាដើម ។

**៣- សង្ខារ** មាន២គឺ ឧបាទិន្នកសង្ខារ១ និង អនុបាទិន្នកសង្ខារ១ ។ ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណគ្រប់គ្រង មានពាក្យថាបុគ្គល មនុស្ស ទេវតា ព្រហ្ម ជាដើម ។ ឯអនុបាទិន្នកសង្ខារ គឺសង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង មានពាក្យថា ដើមដូង, ដើមបេក, ដើមត្នោត, ឈូក, ស្មៅជាដើម ។

**បរមត្ថធម៌** មានសេចក្ដីដ៏ល្អិតក្រៃលែង ដូចជា រូប, នាម, ខន្ធ, អាយតនៈ,ធាតុ, ឥន្ទ្រិយ ។ ល ។ ដែលជាអារម្មណ៍របស់វិបស្សនា ។ បញ្ញត្តិធម៌ ដែលជាឈ្មោះ មិនមែនជាអារម្មណ៍របស់វិបស្សនាទេ ។

# នាម និង រូប

**នាម** ជាធម្មជាតិឱនទៅកាន់អារម្មណ៍ មានកិរិយាឱនទៅកាន់អារម្មណ៍ជា លក្ខណៈ បានដល់អរូបក្ខន្ធ៤ ។

**អរូបក្ខន្ធ** មានន័យថា ក្រុមអរូប៤យ៉ាងគឺៈ វេទនាខន្ធ១, សញ្ញាខន្ធ១, សង្ខារ ក្ខន្ធ១ និង វិញ្ញាណក្ខន្ធ១ ។

**វេទនាខន្ធៈ** ក្រុមសោយអារម្មណ៍ បានដល់វេទនាដែលកើតជាមួយចិត្ត ៨៩ ឬ១២១ដួង ។

**សញ្ញាខន្ធៈ** ក្រុមចាំអារម្មណ៍ បានដល់សញ្ញាដែលកើតឡើងជាមួយចិត្ត ៨៩ ឬ១២១ដួង ។

**សង្ខារក្ខន្ធៈ** ក្រុមតាក់តែងនូវអារម្មណ៍ បានដល់ចេតសិក៥០ គឺចេតសិក ទាំង៥២ ដកយកវេទនាចេតសិក១និងសញ្ញាចេសិក១ចេញ នៅសល់៥០ ។

**វិញ្ញាណក្ខន្ធៈ** ក្រុមដឹងច្បាស់នូវអារម្មណ៍ បានដល់ចិត្ត៨៩ ឬ១២១ដួង ។

វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ លោកហៅថា **នាមធម៌** ព្រោះជាធម្មជាតិតែង ឱនទៅ ទេជ្រទៅ រេទៅកាន់អារម្មណ៍តាមទ្វារ៦ នៅពេលដែលអារម្មណ៍មក ប្រាកដ ដល់ទ្វារទាំងនោះ ។

**រូប** មានន័យ ធម្មជាតិដែលបែកធ្លាយ មានកិរិយាបែកធ្លាយជាលក្ខណៈ បានដល់រូប ក្ខន្ធ ។ រូបក្ខន្ធ មានន័យថា ក្រុមរូប២៨ គឺៈ មហាភូតរូប៤, ឧបាទាយរូប២៤ ។ បណ្ដារូប ទាំង២៨នេះ តែងមានលក្ខណៈផ្សេង ៗ គ្នា មានលក្ខណៈរឹង, រាវ, ក្ដៅ, ល្ហើយ ជាដើម តាមរូបមួយ ៗ ។ តែបើពោលពីលក្ខណៈរួមវិញ មានត្រឹមតែមួយ គឺកិរិយាបែកធ្លាយជា

លក្ខណៈ ព្រោះថារូបទាំង២៨នោះ បើទុកជាមានលក្ខណៈផ្សេងគ្នាយ៉ាងណា ក៏ដោយក៏គង់ត្រូវវិនាស ឬបែកធ្លាយដូចគ្នាទាំងអស់ដែរ ទើបពោលថា រូបក្ខន្ធនេះ ជា **រូបធម៌** ។

## ទ្វារ ៦

**ទ្វារ** មានន័យថា វត្ថុឬសន្ទះ ជាគ្រឿងបិទ គឺថាសង្រួមដោយវត្ថុនោះ (បសាទ រូប) ដូច្នេះវត្ថុនោះហៅថា ទ្វារ ។ ទ្វារនោះមាន៦ គឺៈ

**១- ចក្ខុទ្វារ** ទ្វារភ្នែក សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការឃើញនូវរូប នៅពេលដែលរូបមកប្រាកដដល់ទ្វារភ្នែក ។

**២- សោតទ្វារ** ទ្វារត្រចៀក សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ច



ក្នុងការស្តាប់ នៅពេលដែលសម្លេងមកប្រាកដដល់ទ្វារត្រចៀក ។

**៣- ឃានទ្វារ** ទ្វារច្រមុះ សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការធុំក្លិន នៅពេលដែលក្លិនមកប្រាកដដល់ទ្វារច្រមុះ ។

**៤- ជិវ្ហាទ្វារ** ទ្វារអណ្តាត សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការដឹងរសជាតិ នៅពេលដែលរសជាតិមកប្រាកដដល់ទ្វារអណ្តាត ។

**៥- កាយទ្វារ** ទ្វារកាយ សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការដឹងនូវវត្ថុ នៅពេលដែលវត្ថុមកប៉ះផ្ទប់នឹងទ្វារកាយ ។

**៦- មនោទ្វារ** ទ្វារចិត្ត សំដៅយកភវង្គ មានបាលីថាៈ មនោទ្វារំ បន ភវង្គន្តិ វុច្ចតិ មានន័យថា ភវង្គ ហ្នឹងឯងគឺលោកហៅថា មនោទ្វារ ។

# អារម្មណ៍ ៦

**អារម្មណៈ** មានន័យថា ធម្មជាតិដែលចូលមក ហើយធ្វើចិត្តនិងចេត សិកឲ្យ តោង ជាប់ ឬធ្វើចិត្តនិងចេតសិកឲ្យត្រេកអរ ក្នុងធម្មជាតិនោះ ហៅថា**អារម្មណ៍** ។

អារម្មណ៍មាន៦គឺៈ

**១- រូបារម្មណ៍** អារម្មណ៍គឺរូប មានកិរិយាប៉ះខ្ទប់នឹងចក្ខុបសាទជាលក្ខណៈ បានដល់វណ្ណរូប មានពណ៌ខៀវ លឿង ក្រហម ស ជាដើម ។

**២- សទ្ទារម្មណ៍** អារម្មណ៍គឺសម្លេង មានកិរិយាប៉ះខ្ទប់នឹងសោតបសាទ ជាលក្ខណៈបានដល់សម្លេងស្គរ ពិណ ប៉ី ជាដើម ។

**៣- គន្ធារម្មណ៍** អារម្មណ៍គឺក្លិន មានកិរិយាប៉ះខ្ទប់នឹងឃានបសាទជាលក្ខណៈ បានដល់ក្លិនផ្កាឧប្បល ផ្កាម្លិះ ជាដើម ។

**៤- រសារម្មណ៍** អារម្មណ៍គឺរសជាតិ មានកិរិយាប៉ះខ្ទប់នឹងជិវ្ហាបសាទ ជាលក្ខណៈ បានដល់រសជាតិនៃ ដើម ផ្លែ មើមឈើជាដើម ។

**៥- ផោដ្ឋព្វារម្មណ៍** អារម្មណ៍គឺវត្ថុ ដែលប៉ះខ្ទប់នឹងកាយ បានដល់ធាតុ៣ គឺៈ -បឋវីធាតុ ធាតុដីមានលក្ខណៈរឹង, -តេជោធាតុ ធាតុភ្លើង មានលក្ខណៈក្តៅ, -វាយោធាតុ ធាតុខ្យល់ មានលក្ខណៈល្ហើយ ៗ ។

**៦- ធម្មារម្មណ៍** អារម្មណ៍គឺធម៌ មានលក្ខណៈផ្សេង ៗ គ្នាតាមសភាពធម៌នោះ បានដល់ធម៌៦គឺ បសាទរូប១, សុខុមរូប១, ចិត្ត១, ចេតសិក១, និព្វាន១, វិញ្ញត្តិ១ ។

- **រូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺចក្ខុទ្វារ១, មនោទ្វារ១ ។

- **សម្លេង** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺសោតទ្វារ១, មនោទ្វារ១ ។

- **ក្លិន** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺឃានទ្វារ១, មនោទ្វារ១ ។

- **រស** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺជិវ្ហាទ្វារ១, មនោទ្វារ១ ។

- **រឹង ក្តៅ ល្មើយ** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាម ទ្វារ ២ គឺ កាយទ្វារ១, មនោទ្វារ១ ។

- **ធម្មា** គឺក្រុមធម៌ មានបសាទរូប និងសុខុមរូប ជាដើម នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារតែម្យ៉ាង ។

## សេចក្តីអធិប្បាយថាៈ

កាលដែលរូបារម្មណ៍មកប្រាកដដល់ចក្ខុទ្វារហើយ រូបនោះក៏បានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមចក្ខុទ្វារ ហើយក៏រលត់ទៅ ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះ ហេតុដូច្នេះទើប

ពោលថា រូបនឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ បក្ខុទ្វារ១, មនោទ្វារ១ ។

កាលដែលសទ្ទារម្មណ៍ មកប្រាកដដល់សោតទ្វារហើយ រូបនោះក៏បានមកជាអារម្មណ៍ របស់ចិត្តនិងចេតសិក ដែលកើតតាមសោតទ្វារ ហើយក៏រលត់ទៅ ។ បន្ទាប់មកក៏ បានមក ជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះហេតុដូច្នេះទើប ពោលថា សម្លេងនឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែល កើតតាមទ្វារ២ គឺ សោតទ្វារ១, មនោទ្វារ១ ។

កាលដែលគន្ធារម្មណ៍ មកប្រាកដដល់ឃានទ្វារហើយ រូបនោះក៏បានមកជាអារម្មណ៍ របស់ចិត្តនិងចេតសិក ដែលកើតតាមឃានទ្វារ ហើយក៏រលត់ទៅ ។ បន្ទាប់មកក៏ បានមកជា អារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះ ហេតុដូច្នេះទើប ពោលថា ក្លិននឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ ឃាន ទ្វារ១, មនោទ្វារ១ ។

កាលដែលរសារម្មណ៍ មកប្រាកដដល់ជិវ្ហាទ្វារហើយ រូបនោះក៏បានមកជាអា រម្មណ៍ របស់ចិត្តនិងចេតសិក ដែលកើតតាមជិវ្ហាទ្វារ ហើយក៏រលត់ទៅ ។ បន្ទាប់មកក៏ បានមកជា អារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះ ហេតុដូច្នេះទើប ពោលថា រសជាតិនឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ ជិវ្ហាទ្វារ១, មនោទ្វារ១ ។

កាលដែលផោដ្ឋព្វារម្មណ៍ មកប្រាកដដល់កាយទ្វារហើយ ផោដ្ឋព្វៈនោះក៏បាន មកជា អារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមកាយទ្វារ ហើយក៏រលត់ទៅ ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារ ថែមទៀត ព្រោះហេតុ

ដូច្នេះទើបពោលថា ផោដ្ឋព្វៈនឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិក ដែលកើតតាមទ្វារ២ គឺ កាយទ្វារ១, មនោទ្វារ១ ។

រីឯធម៌ មានបសាទរូបនិងសុខុមរូបជាដើម កាលដែលប្រាកដដល់មនោទ្វារហើយ ក៏បានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារតែម៉្យាងហើយក៏រលត់ទៅ ព្រោះហេតុដូច្នេះទើបពោលថា ធម៌នឹងមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារតែម៉្យាង ។

ចិត្ត និង ចេតសិក ដែលកើតតាមបញ្ចទ្វារ អាចទទួលកាន់យកអារម្មណ៍ជាបច្ចុប្បន្នមួយៗ តាមទ្វាររៀងៗ ខ្លួនមិនអាចកាន់យកនូវអារម្មណ៍ក្នុងអតីតៈនិងអនាគតបានឡើយ ។

ឯចិត្ត និង ចេតសិក ដែលកើតតាមមនោទ្វារ អាចកាន់យកនូវអារម្មណ៍៦ ក្នុងអតីតៈ បច្ចុប្បន្ន និងអនាគតបានទាំងអស់ ។

# កំណត់ដឹងនូវនាមនិងរូប

ក្នុងការចំរើនវិបស្សនាថ្នាក់ដំបូង ដើម្បីបំពេញនូវសេចក្ដីត្រូវការនៃព្រះយោគាវចរ ដែលជាអាទិកម្មិកបុគ្គល សូមលើកយករូបបរមត្ថ និងនាមបរមត្ថ ខ្លះៗ មកបកស្រាយរៀបរៀង ទុកជាក្បួនប្រតិបត្តិក្នុងការហាត់ពត់ អប់រំចិត្តក្នុងព្រះពុទ្ធសាសនា នេះ។

**រូបធម៌**ទាំងអស់ មានចំនួន២៨ គឺមហាភូតរូប៤ និង ឧបាទាយរូប២៤ តែក្នុងទីនេះ សូមលើកយកតែរូបចំនួន៩ មកតាំងទុកជាអារម្មណ៍ របស់បញ្ញានៃព្រះយោគាវចរដែលជាអាទិកម្មិកបុគ្គលដូចតទៅ៖

រូប៩នោះគឺៈ បឋវីធាតុ១, អាបោធាតុ១, តេជាធាតុ១, វាយោធាតុ១, វណ្ណៈ១, គន្ធៈ១, រសៈ១, ឱជៈ១ (រូប៨នេះហៅថា សុទ្ធដ្ឋករូប) និង សទ្ទៈ១ ។

- **បឋវីធាតុ** ធាតុដី មានលក្ខណៈរឹង
- **អាបោធាតុ** ធាតុទឹក មានលក្ខណៈជ្រាបសើម
- **តេជោធាតុ** ធាតុភ្លើង មានលក្ខណៈក្តៅ
- **វាយោធាតុ** ធាតុខ្យល់ មានលក្ខណៈល្ហើយ ៗ
- **វណ្ណៈ** គឺរូបពណ៌ មានកិរិយាប៉ះខ្ទប់នឹងចក្ខុបសាទជាលក្ខណៈ
- **សទ្ទៈ** គឺសម្លេង មានកិរិយាប៉ះខ្ទប់នឹងសោតបសាទជាលក្ខណៈ
- **គន្ធៈ** គឺក្លិន មានកិរិយាប៉ះខ្ទប់នឹងឃានបសាទជាលក្ខណៈ
- **រសៈ** គឺរសជាតិ មានកិរិយាប៉ះខ្ទប់នឹងជីវ្ហាបសាទជាលក្ខណៈ
- **ឱជៈ** គឺឱជា សំដៅយកឱជារសដែលសម្រាប់ចិញ្ចឹមសរីរៈរាងកាយ សត្វឲ្យមានជីវិត ប្រព្រឹត្តទៅក្នុងលោក, ឱជៈនេះផ្សព្វផ្សាយទៅពេញរាងកាយសត្វទាំងមូល មានឱជៈជាលក្ខណៈ ។

**វណ្ណរូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមចក្ខុទ្វារនិងមនោទ្វារ ។

**សទ្ទរូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមសោត ទ្វារនិងមនោទ្វារ ។

**គន្ធរូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមឃានទ្វារនិងមនោទ្វារ ។

**រសរូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមជីវ្ហាទ្វារ

និងមនោទ្វារ ។

**បឋវីធាតុ, តេជោធាតុ, វាយោធាតុ** នឹងបានមកជាអារម្មណ៍របស់ចិត្ត និងចេតសិក ដែលកើតតាមកាយទ្វារនិងមនោទ្វារ ។

**អាបោធាតុ, ឱជរូប** នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមមនោទ្វារតែម៉្យាង ព្រោះរូបទាំងនេះជារូបល្អិត ចិត្តនិងចេតសិកតាមបញ្ចទ្វារ មិនអាចឃើញបាន ។

**នាមធម៌** មានច្រើនបែបយ៉ាង តែសូមលើកតែត្រឹម៥ មកទុកជាអារម្មណ៍របស់វិបស្សនា ។ នាមធម៌៥នោះគឺ ផស្សៈ១, វេទនា១, សញ្ញា១, ចេតនា១, ចិត្ត១ ។

- **ផស្សៈ** ធម្មជាតិប៉ះនូវអារម្មណ៍ មានកិរិយាប៉ះនូវអារម្មណ៍ជាលក្ខណៈ
- **វេទនា** ធម្មជាតិសោយនូវអារម្មណ៍ មានកិរិយាសោយនូវអារម្មណ៍ជាលក្ខណៈ
- **សញ្ញា** ធម្មជាតិចាំនូវអារម្មណ៍ មានកិរិយាចាំនូវអារម្មណ៍ជាលក្ខណៈ
-**ចេតនា** ធម្មជាតិគិតនូវអារម្មណ៍ មានភាពគិត ឬចាត់ចែង ឬភាពសន្សំជា លក្ខណៈ
- **ចិត្ត** គឺវិញ្ញាណ គឺធម្មជាតិដឹងច្បាស់នូវអារម្មណ៍ មានកិរិយាដឹងច្បាស់ជាលក្ខណៈ ។

ក្រុមធម៌ទាំង៥នេះ លោកហៅថា នាមធម៌ តែងកើតឡើងតាមទ្វារទាំង៦ មានចក្ខុទ្វារជាដើម កាន់យកអារម្មណ៍៦ មានរូបារម្មណ៍ជាដើម ក្នុងសម័យដែលប្រាជ្ញា របស់ព្រះយោគីបានកំណត់ដឹងនូវលក្ខណៈនៃសភាវៈធម៌ មានរូបជាដើម ដែលមកប្រាកដដល់ទ្វារ មានចក្ខុទ្វារជាដើម ។

# កំណត់ដឹងនូវបច្ច័យរបស់នាមរូប

ពេទ្យអ្នកឈ្លាសវៃ ឃើញនូវរោគអ្នកជម្ងឺ ក៏ស្វែងរកនូវសមុដ្ឋាននៃរោគនោះ យ៉ាងណា បុរសអ្នកប្រកបដោយសេចក្ដីករុណា ឃើញទារកដ៏ក្មេងខ្ចីកំពុងដេកផ្ងារ ក្នុងព្រៃស្មសាន ហើយក៏ធ្វើការពិចារណាថា តើមាតាបិតារបស់ទារកនេះមួយណាហ្ន៎យ៉ាងណា ព្រះយោគី កាលបើកំណត់ដឹងនូវនាមរូបហើយ ក៏ពិចារណារកហេតុបច្ច័យរបស់នាមរូបនោះ ក៏យ៉ាង នោះដូចគ្នា ។ ការពិចារណារកនូវហេតុបច្ច័យរបស់នាមរូបក្នុងវិបស្សនានេះ ព្រះយោគី ត្រូវពិចារណារកហេតុបច្ច័យរបស់រូបកាយជាមុនសិន ទើបពិចារណារកហេតុបច្ច័យរបស់ នាមកាយជាខាងក្រោយ ។

ហេតុបច្ច័យរបស់រូបកាយមាន៥គឺ អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១, អាហារ១ ។

- **អវិជ្ជា** សេចក្ដីល្ងង់ខ្លៅ
- **តណ្ហា** សេចក្ដីប្រាថ្នា សេចក្ដីតក់ស្លុតក្នុងអារម្មណ៍
- **ឧបាទាន** សេចក្ដីប្រកាន់មាំក្នុងអារម្មណ៍
- **កម្ម** អំពើល្អ និងអំពើអាក្រក់
- **អាហារ** កវឡីង្ការាហារ បានដល់ដុំបាយ ទឹក នំ ចំណី ជាដើម ដែលបុគ្គលបរិភោគ លេបចូលទៅកន្លងបំពង់ក ។

## សេចក្ដីកត់ចំណាំៈ

បុគ្គលម្នាក់ ៗ កើតឡើងមានៈ **ខន្ធ៥** ខន្ធ៥នោះគឺ រូប១, វេទនា១, សញ្ញា១, សង្ខារ១, វិញ្ញាណ១ ។ **អាយតនៈ១២** វិញ្ញាណ៦ (អាយតនៈក្នុង) និង អារម្មណ៍៦ (អាយតនៈក្រៅ) ។

ចំលងចេញពី
**www.visuddhi7.com**
កែប្រែតាមកុំព្យូទ័រដោយ
ខ្ញុំបាទ ស្រុង ចាន់ណា